


## មាតិកា

១. សេចក្តីផ្តើម

២. សមិទ្ធផលក្រោយកំណែទម្រង់

៣. បទពិសោធន៍ការងារខេត្តកណ្តាល

៤. បញ្ហាប្រឈម/សំណូមពរ

2

## ១. សេចក្តីផ្តើម

- ឆ្នាំ ២០០២ មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- ខេត្តកណ្តាល មានការគាំទ្រពីកម្មវិធិសិលា ក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការតាំងពីឆ្នាំ២០០៣ ដោយផ្តោតសំខាន់លើការគាំទ្រ ក្រុមប្រឹក្សាឃុំ សង្កាត់
- ឆ្នាំ ២០០៩ មានការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ចាប់ពីឆ្នាំ២០១១ ការចាប់ផ្តើមអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

3

## ២. សមិទ្ធផលក្រោយកំណែទម្រង់

ក្នុងរយៈពេល ៧ឆ្នាំក្រោយការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ បានបង្ហាញឲ្យឃើញថា រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសថ្នាក់ខេត្ត មានការវិវឌ្ឍន៍ដូចខាងក្រោម៖

- រចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក ត្រូវបានកែសម្រួល ស្របតាមទំហំការងារ និង ស្ថានភាពកំណែទម្រង់ ហើយបានរៀបចំតែងតាំងមន្ត្រីឡើងវិញស្របតាមមុខជំនាញ បានធ្វើឲ្យមន្ត្រីបំពេញការងារ តាមតួនាទី ភារៈកិច្ច បានល្អ ប្រកបដោយមនសិការវិជ្ជាជីវៈដែលធ្វើឲ្យការផ្តល់សេវាមានភាពប្រសើរឡើងជាលំដាប់

4

## ២. សមិទ្ធផលក្រោយកំណែទម្រង់ (ត)

- សមត្ថភាពមន្ត្រីមានកើនឡើង ដោយទទួលបានការរៀនសូត្រ និងស្វែងយល់ពីគោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិ ដែលជាកត្តាជួយជម្រុញការបំពេញតួនាទីភារៈកិច្ច បានល្អប្រសើរផងដែរ



## ២. សមិទ្ធផលក្រោយកំណែទម្រង់ (ត)

- រដ្ឋបាលថ្នាក់ក្រោមជាតិបានបង្កើនស្វ័យភាពរបស់ខ្លួន ស្របតាមច្បាប់ និង មានលទ្ធភាពចាត់ចែងថវិការបស់ខ្លួន ក្នុងការលើកកម្ពស់សុខមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋប្រកបដោយភាពសក្តិសិទ្ធិ តាមរយៈការឆ្លើយតបទាន់ពេលវេលាទៅនឹងសំណូមពរ បញ្ហាប្រឈមនៅមូលដ្ឋាន

6

## ២. សមិទ្ធផលក្រោយកំណែទម្រង់ (ត)

- រដ្ឋបាលខេត្តមានសិទ្ធិគ្រប់គ្រងចំណូលផ្ទាល់ពីពន្ធ និងមិនមែនសារពើពន្ធនៅថ្នាក់ខេត្ត បានធ្វើឲ្យចំណូលនៅខេត្តកណ្ដាល មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ចាប់ពីឆ្នាំ២០១៤ ដែលមានចំណូលប្រមាណ ២០ពាន់លានរៀល កើនឡើងរហូតដល់៤០ពាន់លានរៀលនៅឆ្នាំ២០១៨ ដែលបង្ករលទ្ធភាពឲ្យ រដ្ឋបាលខេត្តសម្រេចចិត្ត ចាត់ចែងប្រើប្រាស់ ក្នុងការឆ្លើយតបនឹងតម្រូវការអាទិភាពបានច្រើនគម្រោង

7

## ២. សមិទ្ធផលក្រោយកំណែទម្រង់ (ត)

- ការងារគណនេយ្យភាពត្រូវបានពង្រឹង តាមរយៈការរៀបចំវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត នៅគ្រប់ក្រុង ស្រុក រៀងរាល់ឆ្នាំ និង តាមរយៈកិច្ចប្រជុំជាសាធារណៈរបស់គណៈអភិបាលខេត្ត ព្រមទាំងបានឆ្លើយតបមានប្រសិទ្ធភាព និងប្រជាពលរដ្ឋរីករាយទទួលយកបាន

8

## ២. សមិទ្ធផលក្រោយកំណែទម្រង់ (ត)

- ប្រតិភូកម្មសិទ្ធិអំណាចឲ្យគណៈអភិបាលខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ ជួយពង្រឹងខ្សែគណនេយ្យភាព រវាង គណៈអភិបាល ក្រុមប្រឹក្សា និង មន្ទីរ អង្គភាព ដែលឈានទៅរកការពង្រឹងរដ្ឋបាលឯកភាព ក្នុងការសម្របសម្រួលការងារអភិវឌ្ឍន៍ក្នុងខេត្តប្រកបដោយសុខដុមនីយកម្ម។

9

## ២. សមិទ្ធផលក្រោយកំណែទម្រង់ (ត)

- តាមរយៈវេទិកា និង កិច្ចប្រជុំជាសាធារណៈ បានលើកទឹកចិត្តឲ្យមានការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋលើសពីការរំពឹងទុក ដែលយើងសង្កេតឃើញថា ប្រជាពលរដ្ឋមានភាពក្លាហាន លើកឡើងបញ្ហាប្រឈម សំណូមពរ របស់ពួកគេ។ លើសពីនេះប្រជាពលរដ្ឋ បានចូលរួមក្នុងការត្រួតពិនិត្យ និង ផ្តល់យោបល់ត្រឡប់តាមរយៈបណ្តាញសង្គម ឬ ប្រអប់សំបុត្រគណនេយ្យភាព លើការអនុវត្តគម្រោង និង ការបំពេញតួនាទីរបស់មន្ត្រីរាជការ។

10

## ២. សមិទ្ធផលក្រោយកំណែទម្រង់ (ត)

សមិទ្ធផលក្រោយកំណែទម្រង់ដែលសម្រេចបានដូចរៀបរាប់ខាងលើ ដោយសារមានការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាលដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី និង ប្តេជ្ញាចិត្តបន្តនិរន្តរភាពនៃការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ នៅថ្នាក់ក្រោមជាតិ ដើម្បីសម្រេចបាននូវគោលបំណងដែលបានគ្រោងទុក។

រដ្ឋបាលខេត្តកណ្តាលបានអនុម័តថវិកា ១ ៩៥៤លានរៀល សម្រាប់បន្តនិរន្តភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការសម្រាប់ឆ្នាំ២០១៨

11

## ២. សមិទ្ធផលក្រោយកំណែទម្រង់ (ត)

ឆ្លៀតក្នុងឱកាសនេះតាងនាមរដ្ឋបាលខេត្តកណ្តាល ខ្ញុំបាទសូមថ្លែងនូវការដឹងគុណជាអតិបរមាគោរពជូនចំពោះក្រសួងមហាផ្ទៃ និង គ.ជ.អ.ប ដែលដឹកនាំដោយសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងការជំរុញ ការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិបានរួមចំណែកយ៉ាងសំខាន់ដល់ភាពជោគជ័យនៃការអនុវត្តយុទ្ធសាស្រ្ត ចតុកោណដំណាក់កាលទី៣។ ក្រសួងមហាផ្ទៃ តែងតែបានយកចិត្តទុកដាក់គាំទ្រ និង ណែនាំជាប់ជាប្រចាំ ដល់រដ្ឋបាលខេត្ត-ក្រុង-ស្រុក-ឃុំ-សង្កាត់ ឲ្យបំពេញតួនាទីភារកិច្ចរបស់ខ្លួនក្នុងឋានៈជាអ្នកបម្រើ និងការពារផលប្រយោជន៍ដ៏ឧត្តុងឧត្តមរបស់ប្រជាពលរដ្ឋពិតប្រាកដ។

12

## ៣. បទពិសោធន៍ការងារខេត្តកណ្ដាល

ខ្ញុំសូមចូលរួមចែករំលែកបទពិសោធន៍ចំនួន ៤ នៅខេត្តកណ្ដាល៖

៣.១. ការអនុវត្ត អនុក្រឹត្យ សារាចរ លិខិតបទដ្ឋានគតិយុត្តិនានា

៣.២. ការប្រើប្រាស់ថវិកាគុណប្រយោជន៍ខេត្តនិងថវិកាដៃគូ/សប្បុរសជន ប្រកបដោយសមធម៌

៣.៣. ការងារអភិវឌ្ឍន៍សមត្ថភាព

៣.៤. ការងារលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម

13

## ៣.១. ការអនុវត្ត អនុក្រឹត្យ សារាចរ លិខិតបទដ្ឋានគតិយុត្តិនានា

អាស្រ័យដោយការតាំងចិត្តខ្ពស់ពីថ្នាក់ដឹកនាំខេត្ត និង មានការចូលរួមយ៉ាងសកម្មពីក្រុមការងារ និងលោកអភិបាលក្រុង ស្រុក ព្រមទាំងអ្នកគ្រប់គ្រងផ្សារ បានធ្វើឲ្យខេត្តកណ្ដាល សម្រេចបានការអនុវត្តន៍ សារាចរលេខ ០៨សរ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦ របស់ រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការគ្រប់គ្រងផ្សារគ្រប់ប្រភេទទូទាំងប្រទេសដោយបានចែកប័ណ្ណទទួលស្គាល់តូប រាន ស្តង់លក់ដូរក្នុងផ្សារគ្រប់ប្រភេទ បាន ៣១៧០/៤៤០០ តូប ស្មើនឹង៧០% និង ១៩១/៣៧៩ រាន ស្មើនឹង៥០%





## ៣.១. ការអនុវត្ត អនុក្រឹត្យ សារាចរ លិខិតបទដ្ឋានគតិយុត្តិនានា (ត)

បានអនុវត្តអនុក្រឹត្យលេខ១១៣ ស្ដីពីការគ្រប់គ្រងសំរាមសំណល់រឹងនៅតាមទីប្រជុំជន ដោយបានវិភាជន៍ថវិកាពីសាលាខេត្តក្នុង ១ស្រុក ៤០ លានរៀន និង ស្រុកនីមួយៗបានរៀបចំជាផែនការយុទ្ធសាស្ត្រគ្រប់គ្រងសំរាម ហើយកំពុងរកដៃគូអនុវត្ត



## ៣.១. ការអនុវត្ត អនុក្រឹត្យ សារាចរ លិខិតបទដ្ឋានគតិយុត្តិនានា (ត)

- បានអនុវត្តអនុក្រឹត្យ ១១៩ ស្ដីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ និង ទិសដៅកាត់បន្ថយកុមារ ៣០% ពីមណ្ឌលថែទាំទៅនៅជាមួយគ្រួសារ ញាត្តិសណ្ដាន ក្នុងមូលដ្ឋាន បានសម្រេច ៧១% នៃផែនការឆ្នាំ២០១៧ ។
- បានរៀបចំសមាគមមនុស្សចាស់ ស្របតាមសរាចរណែនាំ ០០៥ សអយ ចុះថ្ងៃទី២៥ ខែមិថុនាឆ្នាំ២០០៩ សម្រេចបាន ១២៧ឃុំ ស្មើ ១០០% ព្រមទាំងមានថវិកាដំណើរការគ្រប់គ្រាន់ពីថវិកាសមាជិកភាព និង ថវិកាពីសប្បុរសជន ដែលប្រមូលបាន ១ ៥៩៩លានរៀល ក្នុងឆ្នាំ២០១៧ និង មានសមតុល្យសាច់ប្រាក់ ៤៣៥លានរៀលទៀត

16

## ៣.១. ការអនុវត្ត អនុក្រឹត្យ សារាចរ លិខិតបទដ្ឋានគតិយុត្តិនានា (ត)

- លើសពីនេះ រដ្ឋបាលខេត្ត ក៏បានខិតខំអនុវត្តដោយម្ចាស់ការតាមអនុក្រឹត្យ សារាចរ លិខិតបទដ្ឋានគតិយុត្តិនានា ដែលបានដាក់ចេញ និង តាមដានជាប្រចាំ

<u>កត្តាជោគជ័យ</u>

- ថ្នាក់ដឹកនាំមាន ឆន្ទៈ និង ការប្តេជ្ញាចិត្ត អនុវត្តឲ្យបានតាម អនុក្រឹត្យ សារាចរ លិខិតបទដ្ឋានគតិយុត្តិនានា ដោយមិនស្ទាក់ស្ទើរ មិនរង់ចាំ

17

## ៣.១. ការអនុវត្ត អនុក្រឹត្យ សារាចរ លិខិតបទដ្ឋានគតិយុត្តិនានា (ត)

- រាល់ការអនុវត្ត អនុក្រឹត្យ សារាចរ លិខិតបទដ្ឋានគតិយុត្តិ ណាមួយ ត្រូវបានពិភាក្សា និង មានការស្វែងយល់បន្ថែម ប្រកបដោយតម្លាភាព និង គ្មានភាពលម្អៀង ក្នុងជួរក្រុមប្រឹក្សា និង គណៈអភិបាល ដើម្បីជៀសវាងការខ្វះចន្លោះ
- មានការណែនាំច្បាស់លាស់ដល់ក្រុមការងារ ឬអ្នកអនុវត្ត ដើម្បីបង្កើនការយល់ដឹងឲ្យស៊ីជម្រៅ និង មានភាពជឿជាក់នៅពេលអនុវត្ត អនុក្រឹត្យ សារាចរ លិខិតបទដ្ឋានគតិយុត្តិណាមួយ ដែលនាំឲ្យអ្នកអនុវត្តមានភាពឈ្មុះឈ្មុល ជម្នះរាល់ឧបសគ្គ ដើម្បីសម្រេចបានតាមទិសដៅដែលឯកភាពគ្នា

18

## ៣.១. ការអនុវត្ត អនុក្រឹត្យ សារាចរ លិខិតបទដ្ឋានគតិយុត្តិនានា (ត)

- រាល់ការអនុវត្ត មានការប្រជុំតាមដានជាប្រចាំពី ថ្នាក់ដឹកនាំខេត្ត ដើម្បីពិភាក្សា បញ្ហាប្រឈមនានា និង រួមគ្នារកដំណោះស្រាយ ដែលនាំឲ្យដំណើរការមានភាពរលូន និង ទទួលបានជោគជ័យ
- មានការគាំទ្រពីថ្នាក់ដឹកនាំខេត្ត ពីអង្គការដៃគូ និង មានកិច្ចសហការល្អ ពីមន្ទីរ ស្ថាប័នពាក់ព័ន្ធ និង មានការចូលរួមពីប្រជាពលរដ្ឋ។





## ៣.១. ការអនុវត្ត អនុក្រឹត្យ សារាចរ លិខិតបទដ្ឋានគតិយុត្តិនានា (ត)

<u>បញ្ហាប្រឈម៖</u>

មានលិខិតបទដ្ឋានគតិយុត្តិមួយចំនួន ទាក់ទងការផ្ទេរ ការប្រគល់មុខងារមកថ្នាក់ក្រោមជាតិ អនុវត្តមិនទាន់បាន ដោយសារកត្តា ៣៖ ១) រដ្ឋបាលថ្នាក់ក្រោមជាតិមិនយល់ច្បាស់ នាំឲ្យមានការស្ទាក់ស្ទើរក្នុងការអនុវត្ត ២)ការអនុវត្តខ្លះ ត្រូវការធនធាន ដែលរដ្ឋបាលខេត្តមិនមានលទ្ធភាពគាំទ្រ ៣)ស្ថាប័នជំនាញពាក់ព័ន្ធ មិនទាន់ទទួលបានការបណ្តុះបណ្តាលស៊ីជម្រៅ នាំឲ្យការចូលរួមមិនបានពេញលេញ។

20

## ៣.១. ការអនុវត្ត អនុក្រឹត្យ សារាចរ លិខិតបទដ្ឋានគតិយុត្តិនានា (ត)

ឧទាហរណ៍៖

១)ការអនុវត្តអនុក្រឹត្យលេខ ១១៣ អនក្របក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងនៅទីប្រជុំជន មិនទាន់ដំណើរការល្អនៅឡើយទោះបីជាខេត្តបានវិភាជន៍ថវិកាគាំទ្រក្នុងមួយស្រុក ៤០ លានរៀលក៏ដោយ ដោយសារបញ្ហាចម្បង ទី១. ខ្វះទីតាំងចាក់សម្រាម និង ទី២. អ្នកវិនិយោគក្នុងស្រុកមានការរារែកដោយការវិនិយោគចំណាយខ្ពស់

២)ដំណើរការចែកប័ណ្ណសម្គាល់ តូប រាន ស្តង់ លក់ដូរក្នុងផ្សារឯកជន (ទាំងដីក៏ឯកជន និង សំណង់ក៏វិនិយោគដោយឯកជន) ប្រើពេលវេលាដោះស្រាយជាមួយម្ចាស់ផ្សារ ដោយសារលក្ខ័ណ្ឌមួយចំនួនក្នុងសារាចរណែនាំលេខ០៨សរ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលកម្ពុជា ធ្វើឲ្យម្ចាស់ផ្សារឯកជនយល់ថាពួកគេខាតបង់។

21

## ៣.២. ការប្រើប្រាស់ថវិកាគុណប្រយោជន៍ខេត្ត និង ថវិកាដៃគូ/សប្បុរសជន ប្រកបដោយសមធម៌

រដ្ឋបាលខេត្តកណ្តាលបានធ្វើការសម្រេចចិត្តបែងចែកថវិកាគុណប្រយោជន៍ ខេត្តប្រកបដោយសមធម៌ គឺគាំទ្រគម្រោងអាទិភាពទាំងនៅទីប្រជុំជន និង នៅជនបទ តាមក្រុង ស្រុក ប្រហាក់ប្រហែលគ្នា ហើយការវិភាជន៍ថវិកា មិនផ្តោតការយកចិត្តទុកដាក់តែលើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្លូវថ្នល់ទេ តែបានគាំទ្រការសាងសង់សាលាឃុំ សាលាស្រុក គម្រោងសេវាសង្គម ជលផល ទប់ស្កាត់ការជួញដូរ អភិវឌ្ឍន៍សមត្ថភាព បរិស្ថាន ដែលជាមុខងារជាអាណត្តិទូទៅ (មុខងារជាជម្រើស) របស់ក្រុមប្រឹក្សា និង បានបង្ហាញពីតុល្យភាពរវាងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង អរូបវន្តថែមទៀត និងបានខិតខំគៀរគរធនធានពី ក្រសួងដៃគូអភិវឌ្ឍន៍ សប្បុរសជន ក្រុមការងារ និង ការចូលរួមពីប្រជាពលរដ្ឋ ដើម្បីឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍ជាច្រើននៅមូលដ្ឋាន ។

22

## ៣.២. ការប្រើប្រាស់ថវិកាគុណប្រយោជន៍ខេត្ត និង ថវិកាដៃគូ/សប្បុរសជន ប្រកបដោយសមធម៌ (ត)

ក្រៅពីនេះ ក៏នៅមានសមិទ្ធផលសង្គមផ្សេងៗទៀត ដូចជា៖

១)បានជួយសាងសង់សាលារៀន និង គាំទ្រលើកទឹកចិត្តសិស្ស គ្រូ មុន និង ក្រោយប្រឡងបាក់ឌុប រៀបចំកាយរិទ្ធិ ព្រមទាំងជម្រុញបង្កើនមត្តេយ្យរដ្ឋ និង មត្តេយ្យសហគមន៍ ដែលជាមូលដ្ឋានសំខាន់នៃវិស័យអប់រំ

២)បានជួយសាងសង់មណ្ឌលសុខភាព និង អាគារមន្ទីរពេទ្យចាំបាច់នានា ព្រមទាំងគាំទ្រស្ត្រីក្រីក្រឆ្លងទន្លេ

៣)គាំទ្រប្រេងឥន្ធនៈលើវិស័យគ្រប់គ្រងបទល្មើសជលផល

៤)គាំទ្រសកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀន

៥)គាំទ្រលើកទឹកចិត្តអតីតយុទ្ធជន និវត្តន៍ជន និងទិវានារីអន្តរជាតិ។ល។

៦)យកចិត្តទុកដាក់ ការងារមនុស្សធម៌គាំទ្រជនងាយរងគ្រោះ និងជនរងគ្រោះ។

## ៣.២. ការប្រើប្រាស់ថវិកាគុណប្រយោជន៍ខេត្ត និង ថវិកាដៃគូ/សប្បុរសជន ប្រកបដោយសមធម៌ (ត)

**កត្តាជោគជ័យ៖**

- បានធ្វើការផ្លាស់ប្តូរ ពីការអភិវឌ្ឍផ្តោតនៅតែជុំវិញក្រុង ទៅផ្តោតទីជនបទប្រកបដោយសមធម៌





## ៣.២. ការប្រើប្រាស់ថវិកាគុណប្រយោជន៍ខេត្ត និង ថវិកាដៃគូ/សប្បុរសជន ប្រកបដោយសមធម៌ (ត)

<u>កត្តាជោគជ័យ៖</u>

- ត្រូវមានការត្រួតពិនិត្យដំណើរការវិភាជន៍ថវិកាគុណប្រយោជន៍ខេត្ត ដោយបង្កើនការចូលរួមពីអ្នកពាក់ព័ន្ធ ជាពិសេសពីថ្នាក់ដឹកនាំក្រុងស្រុក ដើម្បីធានាពី តម្លាភាព សមភាពនៃការបែងចែកថវិកាតាមក្រុងស្រុក និង ប្រកដជាឆ្លើយតបចំតម្រូវការរបស់មូលដ្ឋាន ព្រមទាំងធានាឲ្យមានតុល្យភាពរវាងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និង អរូបវ័ន្ត





25

## ៣.២. ការប្រើប្រាស់ថវិកាគុណប្រយោជន៍ខេត្ត និង ថវិកាដៃគូ/សប្បុរសជន ប្រកបដោយសមធម៌ (ត)

•ការខិតខំគ្រប់គ្រងចំណូលពីពន្ធ និង មិនមែនសារពើពន្ធ នៅថ្នាក់ខេត្ត បានធ្វើឲ្យចំណូលមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ចាប់ពីឆ្នាំ២០១៤ ដែលមានចំណូលប្រមាណ ២០ពាន់លានរៀល បានកើនឡើងរហូតដល់ ៤០ពាន់លានរៀលនៅឆ្នាំ២០១៨ ដែលបង្ករលទ្ធភាពឲ្យរដ្ឋបាលខេត្តគ្រោងចំណាយបានខ្ពស់៖

| បរិយាយ | ឆ្នាំ ២០១៤ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ២០១៨ |
|---|---|---|---|---|---|
| គ្រោងចំណូល | ១៥ពាន់លាន | ២១ពាន់លាន | ២៥ពាន់លាន | ៤១ពាន់លាន | ១៥ពាន់លាន |
| ចំណូលជាក់ស្តែង | ២៥ពាន់លាន | ៣៣ពាន់លាន | ៥៤ពាន់លាន | ២៥ពាន់លាន | |
| %កើនឡើងធៀបគ្រោង | ៦៧% | ៥៧% | ១១៦% | ៦៧% | |

•ថ្នាក់ដឹកនាំ ត្រូវមានគំនិតផ្តួចផ្តើមក្នុងការគៀរគរធនធានពីប្រភពផ្សេងៗ ដើម្បីឆ្លើយតបនឹងតម្រូវការអាទិភាពរបស់មូលដ្ឋានបានទាន់ពេលវេលា ទាំងនៅទីប្រជុំជន និង ទីជនបទ ដែលបានជួយលើកកម្ពស់ភាពជឿជាក់លើការដឹកនាំរបស់រាជរដ្ឋាភិបាល និង អាជ្ញាធរមូលដ្ឋាន។

26

## ៣.២. ការប្រើប្រាស់ថវិកាគុណប្រយោជន៍ និង ថវិកាដៃគូ/សប្បុរសជន ខេត្តប្រកបដោយសមធម៌ (ត)







សមិទ្ធផលនានាដែលសម្រេចបាននៅខេត្តកណ្ដាល

## ៣.២. ការប្រើប្រាស់ថវិកាគុណប្រយោជន៍ខេត្ត និង ថវិកាដៃគូ/សប្បុរសជន ប្រកបដោយសមធម៌ (ត)






សមិទ្ធផលនានាដែលសម្រេចបាននៅខេត្តកណ្ដាល

### ៣.២. ការប្រើប្រាស់ថវិកាគុណប្រយោជន៍ខេត្ត និង ថវិកាដៃគូ/សប្បុរសជន ប្រកបដោយសមធម៌ (ត)

<u>បញ្ហាប្រឈមៈ</u>

ទោះបីជាមានការខិតខំប្រឹងប្រែងរបស់រដ្ឋបាលខេត្ត ក្នុងការបង្កើនចំណូល និង បានឆ្លើយតបនឹងគម្រោងអាទិភាពជាច្រើនហើយក៏ដោយក៏សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋដែលបានលើកឡើងក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ និង កិច្ចប្រជុំជាសាធារណៈ ពិតជានៅត្រូវការការគាំទ្រពីស្ថាប័នថ្នាក់ជាតិ ដូចជា ប្រព័ន្ធធារាសាស្ត្រដែលបច្ចុប្បន្នមិនទាន់មានលទ្ធភាពស្រោចស្រព លើផ្ទៃដី កសិកម្មបានគ្រប់គ្រាន់នៅឡើយ ផ្លូវថ្នល់អន្តររដ្ឋបាលដែលមានប្រវែងវែងៗ ការពង្រីកបណ្តាញទឹកស្អាត តម្លៃអគ្គីសនីមានភាពខុសគ្នាពីឃុំមួយទៅឃុំមួយមានទីតាំងជាប់គ្នា (ដោយសារអាជ្ញា ប័ណ្ណខុសគ្នា) និង ការពង្រីកទីផ្សារកសិផល ជាដើម ដែលកិច្ចការទាំងនេះហួសពីសមត្ថភាពរបស់ខេត្ត។

29

### ៣.៣. ការអភិវឌ្ឍសមត្ថភាព

ថ្នាក់ដឹកនាំខេត្ត តែងតែផ្តល់ទស្សនទាននៃការកសាងធនធានមនុស្សបន្តវេន និងបានចូលរួមយ៉ាងសកម្ម ក្នុងដំណើរការអភិវឌ្ឍសមត្ថភាព និងបានវិភាជន៍ថវិកាគាំទ្រផែនការអន្តរាគមន៍អភិវឌ្ឍន៍ស្ថាប័នតាំងពីឆ្នាំ ២០១៥ បន្ថែមលើថវិកាផអ៣ ដែលផ្តល់លទ្ធភាពឲ្យមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត រៀបចំគម្រោងអ្នកដឹកនាំវ័យក្មេងជំនាន់ទី១ និង គម្រោងអ្នកដឹកនាំវ័យក្មេងជំនាន់ទី២និងកសាងសមត្ថភាពរហូតដល់ថ្នាក់ឃុំ សង្កាត់។

ជាលទ្ធផលមន្ត្រីភាគច្រើន មានការផ្លាស់ប្តូរ ទស្សនៈ ឥរិយាបថ បំពេញការងារបានល្អប្រសើរប្រកបដោយប្រសិទ្ធភាព (ពីទស្សនត្រួតត្រាមកជាអ្នកបម្រើប្រជាពលរដ្ឋ)





## ៣.៣._ការអភិវឌ្ឍសមត្ថភាព (ត)

<u>កត្តាជោគជ័យ៖</u>

- ថ្នាក់ដឹកនាំមានចក្ខុវិស័យច្បាស់លាស់ ក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ដោយ ១)ធ្វើការអភិវឌ្ឍធនធានមនុស្ស ២)ពង្រឹងរបៀបរបការងារដឹកនាំ ការអនុវត្តតួនាទី ភារៈកិច្ច ស្របតាមជំនាញ បទពិសោធន៍ និង ៣)ធ្វើការផ្លាស់ប្តូរ ទស្សនៈ ឥរិយាបថ របស់មន្ត្រី
- ថ្នាក់ដឹកនាំចាំបាច់ត្រូវស្វែងយល់ពីតម្រូវការពិតរបស់មន្ត្រីក្រោមឱវាទ និងពីសារសំខាន់ នៃផែនការអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាព
- ផែនការសកម្មភាពនិងថវិកាលម្អិត ត្រូវកំណត់ក្រុមគោលដៅជាក់លាក់ ប្រធានបទច្បាស់លាស់ យុទ្ធសាស្ត្រសមស្រម ដើម្បីទាក់ទាញការគាំទ្រពី ក្រុមប្រឹក្សា និង គណៈអភិបាលខេត្ត
- គណៈកម្មាធិការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សខេត្ត បានខិតខំបំពេញការងារយ៉ាងសកម្ម និង មានយន្តការតាមដានច្បាស់លាស់ ព្រមទាំងធ្វើការកែលម្អវគ្គហ្វឹកហ្វឺនជាប្រចាំ

31

## ៣.៣._ការអភិវឌ្ឍសមត្ថភាព (ត)

- លទ្ធផលនៃការសិក្សា និងការស្រាវជ្រាវ លើសិក្ខាកាមអ្នកដឹកនាំវ័យក្មេងជំនាន់ទី១ បានបង្ហាញលទ្ធផលគួរឲ្យកត់សម្គាល់មួយចំនួន ដូចជា ១)សិក្ខាកាមទទួលបាននូវចំណេះដឹងនិងបទពិសោធន៍ថ្មីៗ ២)មានភាពក្លាហាន និង មានការផ្លាស់ប្តូរឥរិយាបថល្អសម្រាប់ ស្ថាប័ន និង សិក្ខាកាម ៤៨% នៃសិក្ខាកាមសរុប ២៥នាក់ ក្នុងនោះស្ត្រីមាន៦៧% ត្រូវបានថ្នាក់ដឹកនាំខេត្តជឿទុកចិត្ត តំឡើង តួនាទី ជាថ្នាក់ដឹកនាំការិយាល័យ, ទីចាត់ការ និង ជាអភិបាលរងក្រុង ស្រុក។

វគ្គអ្នកដឹកនាំវ័យក្មេងជំនាន់ទី២



## ៣.៣._ការអភិវឌ្ឍសមត្ថភាព (ត)



វគ្គភាពជាអ្នកដឹកនាំដល់ មេឃុំ ចៅសង្កាត់ រយៈពេល ២ថ្ងៃ បែងចែកជា ៣ក្រុម



វគ្គណែនាំពីការអនុវត្តផែនការសកម្មភាពនិងថវិកាផអ៣

## ៣.៣._ការអភិវឌ្ឍសមត្ថភាព (ត)

<u>បញ្ហាប្រឈម៖</u>

សមត្ថភាព និងចំនួនមន្ត្រីជាគ្រូសម្របសម្រួលនៃមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស មានចំនួនតិច មិនអាចឆ្លើយតបនឹងតម្រូវការ (សំណើរ) របស់រដ្ឋបាលក្រុង ស្រុក ទាន់ពេលវេលា។ វាជាការចាំបាច់ ពេលខ្លះត្រូវការជួលអ្នកផ្តល់សេវាបណ្តុះបណ្តាលឯកជន ដើម្បីចូលរួមសម្របសម្រួល និង ត្រូវព្យាយាមលើកទឹកចិត្ត និងបង្កើនធនធានមនុស្សជាគ្រូឧទ្ទេស ។



## ៣.៤ ការងារលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម

គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារខេត្ត (គ.ក.ស.ក) បានបំពេញមុខងារប្រកបដោយប្រសិទ្ធភាព និង ទទួលបានជោគជ័យជាបន្តបន្ទាប់ តាមរយៈការបង្កើនលទ្ធភាពអនុវត្តមុខងារដែលមានចែងក្នុងលិខិតបទដ្ឋាន ដោយមានការជួយគាំទ្រទាំងស្មារតី និងថវិកា ពីរដ្ឋបាលខេត្ត






## ៣.៤ ការងារលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម (ត)

លទ្ធផលគួរឲ្យកត់សម្គាល់ គឺចំនួនស្ត្រីក្នុងតួនាទីសម្រេចចិត្តក្នុងជួររដ្ឋបាលខេត្ត (ចាប់ពីអនុប្រធានការិយាល័យឡើង) មានការកើនឡើងដល់ ៣១% នាឆ្នាំ២០១៧




36

## ៣.៤ ការងារលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម (ត)

**កត្តាជោគជ័យ៖**

- ថ្នាក់ដឹកនាំត្រូវកសាង ទស្សនៈ និងឆន្ទៈ ក្នុងការលើកស្ទួយស្ថានភាពស្ត្រី កុមារ និង ជនងាយរងគ្រោះ ព្រោះវាជាកត្តាមួយរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ជាតិ
- ទស្សនៈច្បាស់លាស់ របស់ថ្នាក់ដឹកនាំខេត្ត ក្នុងការជម្រុញឲ្យ គ.ក.ស.ក ដំណើរការទៅមុខ ក្រោយពីការបង្កើតហើយ គឺ "បើមិនមានថវិកាមិនមានដំណើរការ" ដូច្នេះទោះបីជាការតស៊ូមតិស្នើថវិកាពីខេត្តមិនបានក៏ក្រុមប្រឹក្សាបានរៃអង្គាសពីសមាជិកដោយស្ម័គ្រចិត្តបានចំនួន ៩៣៥ដុល្លារ ជាការចាប់ផ្តើម





## ៣.៤ ការងារលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម (ត)

- គ.ក.ស.ក មានផែនការសកម្មភាព និងថវិកាច្បាស់លាស់ ហើយបង្ហាញពីការប្តេជ្ញាចិត្តខ្ពស់ សម្រេចបានលទ្ធផលជាផ្លែផ្កា តាមការគ្រោងទុក ជាការទាក់ទាញការគាំទ្រពីថ្នាក់ដឹកនាំខេត្ត
- ក្រុមប្រឹក្សា និង គណៈអភិបាល បានស្វែងយល់ពីច្បាប់ និងលិខិតបទដ្ឋានបន្ថែម ដែលឈានដល់ការធ្វើសេចក្តីសម្រេចចិត្តសាកល្បងធ្វើការវិភាជន៍ថវិកាពីថវិកាខេត្ត សម្រាប់គាំទ្រសកម្មភាព របស់ គ.ក.ស.ក និង សកម្មភាពផ្សេងៗទៀត

**សកម្មភាពនានា របស់ គ.ក.ស.ក និង គ.ក.ន.ក**





## ៣.៤ ការងារលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម (ត)

ការខិតខំប្រឹងប្រែង តែ គ.ក.ស.ក ខេត្ត មិនគ្រប់គ្រាន់ទេ សម្រាប់ការលើកស្ទួយស្ថានភាពយេនឌ័រ បរិយាប័ន្ន និង សមធម៌សង្គម តែវាចាំបាច់ត្រូវមានការចូលរួមទាំងអស់គ្នាទាំង ស្មារតី និង ថវិកា ពីគ្រប់ភាគី





## ៤. បញ្ហាប្រឈម/សំណូមពរ

សរុបមក រដ្ឋបាលថ្នាក់ក្រោមជាតិនៅឃើញមានបញ្ហាប្រឈមមួយចំនួនក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ៖

- ភាពមិនច្បាស់លាស់ក្នុងការបែងចែកមុខងារជាអណត្តិទូទៅ(មុខងារជាជម្រើស) និងការទទួលខុសត្រូវក្នុងការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន រវាងខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និង អង្គភាពវិស័យនានា
- ទោះបីជាមានការសម្របសម្រួលបានល្អរវាងរដ្ឋបាលខេត្ត និង មន្ទីរ

វិស័យ ក្នុងការរៀបចំកិច្ចការអភិវឌ្ឍន៍ ប៉ុន្តែរដ្ឋបាលខេត្តមិនទាន់ជារដ្ឋបាលឯកភាពពេញលេញដែលអាចគ្រប់គ្រងលើគ្រប់វិស័យ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួននៅឡើយ។ ធនធានសម្រាប់ការផ្តល់សេវា និងអភិវឌ្ឍសេដ្ឋកិច្ច បានប្រមូលផ្តុំមួយចំនួនឆ្លើយតបនឹង ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ប៉ុន្តែមួយផ្នែក នៅរាយប៉ាយដែលរដ្ឋបាលខេត្តមិនទាន់អាចគ្រប់គ្រងបាន

40

## ៤. បញ្ហាប្រឈម/សំណូមពរ ( ត )

- ការធ្វើអធិការកិច្ច និង សវនកម្ម ពិតជាមានសារសំខាន់មិនអាចអត់បាន ប៉ុន្តែរយៈកាលកន្លងមក រដ្ឋបាលខេត្ត ទទួលការធ្វើអធិការកិច្ច និងសវនកម្ម ពីក្រសួង ស្ថាប័នថ្នាក់ជាតិជាច្រើន លើការអនុវត្តរបស់រដ្ឋបាលខេត្ត

**ខ្ញុំសូមលើកសំណូមពរមួយចំនួន ដើម្បីធ្វើការពិចារណា៖**

- គួរមានការបែងចែកមុខងារជាអណត្តិទូទៅ (មុខងារជាជម្រើស) និងការទទួលខុសត្រូវច្បាស់លាស់ រវាងខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និង អង្គភាពវិស័យនានា

41

## ៤. បញ្ហាប្រឈម/សំណូមពរ (ត)

- គួរគាំទ្រ ការរៀបចំឱ្យរដ្ឋបាលខេត្តក្លាយជារដ្ឋបាលឯកភាពតំណាងឱ្យរដ្ឋាភិបាលថ្នាក់ជាតិ ដែលមានតួនាទីសម្របសម្រួលជាមួយក្រសួង ស្ថាប័នជំនាញ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ដើម្បីកៀរគរធនធានផ្តល់ការគាំទ្រទៅរដ្ឋបាល ក្រុង ស្រុក និងឃុំ សង្កាត់ក្នុងការផ្តល់សេវា និង ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ប្រកបដោយសុខដុមនីយកម្ម
- គួរពិនិត្យឡើងវិញពីយន្តការអធិការកិច្ច និងសវនកម្ម នៅថ្នាក់ក្រោមជាតិ។

42



# សូមអរគុណ

43